

*Photography: © Sebastia Galbany*

# ចាប់ផ្តើមអាជីពប្រកបដោយភាពច្នៃប្រឌិតរបស់អ្នកនៅ សាលាជំនាញសិល្បៈសូនរូប

## សៀវភៅមគ្គុទ្ទេសក៍

## កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ

**សាលាជំនាញសិល្បៈសូនរូប**

ទំនាក់ទំនង: **+855 (0)12 55 61 663; 096700 4615**

ដាក់ពាក្យចូលរៀនតាមប្រព័ន្ធអនឡាញ:**https://phareps.org/vaas-apply-now/**

តាមសារអេឡិចត្រូនិក: **admissions@phareps.org**

Facebook.com/phareVAAS

Phareps.org/about-us-vaas

ហ្វារពន្លឺសិល្បៈ
Phare Ponleu Selpak
សាលាជំនាញសិល្បៈសូនរូប
VISUAL & APPLIED ARTS SCHOOL

# តារាងមាតិកា

សេចក្តីផ្តើម ... ៣
តើអ្វីទៅជាសាលាជំនាញសិល្បៈសូនរូប? ... ៣
ហេតុអ្វីសិក្សាជំនាញសិល្បៈ និងសូនរូប? ... ៣
កម្មវិធីសិក្សារបស់សាលា ... ៤
ថ្នាក់រៀនត្រៀម ... ៤
កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ... ៤
សកម្មភាពកម្មវិធីសិក្សា ... ៥
មុខវិជ្ជាសិក្សា ... ៥
តើអ្នកណាអាចស្នើសុំចូលរៀនបាន? ... ៦
កម្មវិធី និងថ្ងៃសិក្សា ... ៧
ជំនួយហិរញ្ញវត្ថុសម្រាប់សិស្ស ... ៨
តើអ្នកណាអាចទទួលបានជំនួយហិរញ្ញវត្ថុនេះ? ... ៨
អាហារូបករណ៍ ... ៨
កញ្ចប់ជំនួយហិរញ្ញវត្ថុ ... ៨
ឧទាហរណ៍នានានៃជំនួយហិរញ្ញវត្ថុ ... ៩
តើខ្ញុំត្រូវស្នើសុំជំនួយហិរញ្ញវត្ថុដោយរបៀបណា? ... ៩
របៀបស្នើសុំចូលរៀន ... ១០
ផ្លាស់មកកាន់ខេត្តបាត់ដំបង ... ១២
ទស្សនៈទានរបស់សិស្ស ... ១៣
ឱកាសការងារ ... ១៤

# សេចក្តីផ្តើម

*ហ្វារពន្លឺសិល្បៈជឿជាក់យ៉ាងមុតមាំលើថាមពលនៃសិល្បៈដើម្បីផ្លាស់ប្តូរជីវិត។*

**តើអ្វីទៅជាសាលាជំនាញសិល្បៈសូនរូប?**

សាលាជំនាញសិល្បៈសូនរូប (VAAS) ជាសាលារៀនមួយក្នុងអង្គការហ្វារពន្លឺសិល្បៈ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៦ ដោយមានការគាំទ្រពីដៃគូសហការណ៍ផ្តល់ជំនួយ AFD និង CCFD។ សាលាផ្តល់ជូនសិស្សនូវការបណ្តុះបណ្តាលវិជ្ជាជីវៈលើការរចនាក្រាហ្វិក គំនូរជីវចល និងសិល្បៈសូនរូប។ កម្មវិធីជំនាញវិជ្ជាជីវៈដែលបានផ្តល់ជូននៅសាលាជំនាញសិល្បៈសូនរូប នឹងជួយសិស្សសម្រាប់ឧស្សាហកម្មប្រកបដោយភាពច្នៃប្រឌិតនាពេលអនាគតរបស់ប្រទេសកម្ពុជា និងសេដ្ឋកិច្ចផ្អែកលើមូលដ្ឋានគុណភាព។ នៅបរិវេណសាលា អង្គការហ្វារពន្លឺសិល្បៈក៏មានផងដែរនូវមត្តេយ្យសិក្សា សាលាសម្តែងសិល្បៈ តន្ត្រី រាំ ល្ខោន ព្រមទាំងកម្មវិធី សៀកដ៏ល្បីល្បាញជាអន្តរជាតិ។ សេវាជួយដល់សង្គមដែលបានរួមបញ្ចូលគ្នាត្រូវបានផ្តល់ជូនសិស្សគ្រប់ៗរូប។ សម្រាប់ព័ត៌មានបន្ថែមអំពីសាលា សូមចូលទៅកាន់គេហទំព័ររបស់អង្គការហ្វារពន្លឺសិល្បៈ។

**ហេតុអ្វីសិក្សាជំនាញសិល្បៈ និងសូនរូប?**

ការរចនាក្រាហ្វិក គំនូរជីវចល និងសិល្បៈសូនរូបគឺជាផ្នែកមួយដែលជាសក្តានុពលនៃកំណើនការងារនៅក្នុងទីផ្សារការងារបច្ចុប្បន្ន និងអនាគតនៅក្នុងប្រទេសកម្ពុជា និងអន្តរជាតិ។ សិស្សដែលបានបញ្ចប់វគ្គ បណ្តុះបណ្តាលវិជ្ជាជីវៈនៅសាលាជំនាញសិល្បៈ និងសូនរូប អាចបម្រើការងារនៅក្នុងវិស័យទាំងនេះ រួមមាន ភាពជាម្ចាស់ការលើការងារប្រកបអាជីវកម្មផ្ទាល់ខ្លួន ឬបម្រើការងារឲ្យក្រុមហ៊ុន ឬអង្គការនានា។ ដើម្បីធានាបាននូវការងាររឹងមាំសម្រាប់សិស្សដែលបានបញ្ចប់ការសិក្សា សាលាជំនាញសិល្បៈ និងសូនរូប មានបណ្តាញទំនាក់ទំនងជាមួយក្រុមហ៊ុនជាង ៤០ នៅទូទាំងប្រទេសកម្ពុជា។

១០០% នៃសិស្សដែលបានបញ្ចប់ការសិក្សាពីសាលាជំនាញសិល្បៈ និងសូនរូប ទទួលបានការងារមានប្រាក់ឈ្នួល ក្នុងរយៈពេលមួយឆ្នាំក្រោយពេលបញ្ចប់ការសិក្សា។



**កម្មវិធីសិក្សារបស់សាលា**

សាលាជំនាញសិល្បៈសូនរូបមានបើកវគ្គបណ្តុះបណ្តាលផ្នែកសិល្បៈចំនួន ៤កម្រិត ដូចជា ថ្នាក់ក្រៅម៉ោងសម្រាប់សិស្សតូចៗ ថ្នាក់សិក្សាទ្រឹស្តីសម្រាប់មនុស្សពេញវ័យដែលមិនធ្លាប់មានបទពិសោធន៍ ថ្នាក់រៀនត្រៀមសម្រាប់សិស្សដែលចង់ចូលរៀនថ្នាក់វិជ្ជាជីវៈ និងថ្នាក់សម្រាប់កម្មវិធីបណ្តុះបណ្តាល និងអប់រំបែបវិជ្ជា ជីវៈ។ សៀវភៅមគ្គុទ្ទេសក៍នេះ ផ្តោតលើកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈតែប៉ុណ្ណោះ។

**ប្រសិនបើសិស្សមានអាយុក្រោម ១៦ឆ្នាំ សូមចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំ ឬទំនាក់ទំនងដើម្បីទទួលបានព័ត៌មានបន្ថែមអំពីថ្នាក់សិក្សាក្រៅម៉ោង និងថ្នាក់សិក្សាទ្រឹស្តី។**

**ថ្នាក់រៀនត្រៀម**

វគ្គសិក្សារយៈពេល ១ឆ្នាំនេះនឹងបង្រៀនអ្នកអំពីជំនាញសិល្បៈ និងការសូនរូប។ ប្រសិនបើអ្នកទទួលបានពិន្ទុល្អ (មធ្យមភាគប្រចាំឆ្នាំលើស ៥០%) នៅចុងឆ្នាំនោះ អ្នកអាចចូលធ្វើតេស្តសម្ភាសន៍ ព្រមទាំងអាចចូលរៀនកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈបានហើយ។

**កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ**

សិស្សទាំងអស់ត្រូវរៀនថ្នាក់មូលដ្ឋាន និងជ្រើសរើសជំនាញពិសេសមួយ ដូចជា គំនូរជីវចល ការរចនាក្រាហ្វិក ឬសិល្បៈសូនរូប។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេល ៣ឆ្នាំនេះនឹងជួយឲ្យសិស្សមានជំនាញបទពិសោធន៍ និងបណ្តាញទំនាក់ទំនងក្នុងការស្វែងរកការងារទទួលបានប្រាក់ឈ្នួល ព្រមទាំងបង្កើតអាជីពពិតប្រាកដមួយ។

**កម្មវិធីសិក្សាប្រកបដោយគុណភាព**: ដើម្បីបំពេញតាមតម្រូវការឧស្សាហកម្ម សាលាជំនាញសិល្បៈសូនរូបបានធ្វើបច្ចុប្បន្នភាពនូវកម្មវិធីសិក្សាជាប្រចាំ។ សិស្សនៅសាលាជំនាញសិល្បៈសូនរូប ក្នុងហេតុផលនេះហើយបានឈនៅលំដាប់ទី១ ដែលមានក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុកជាច្រើនចង់បាន។

**កម្មវិធីកម្មសិក្សា**: សិស្សទាំងអស់ដែលសិក្សាកម្មវិធីជំនាញវិជ្ជាជីវៈត្រូវបំពេញកម្មសិក្សាវិជ្ជាជីវៈ រយៈពេល ២ខែ នៅចន្លោះឆ្នាំទី ២ និងឆ្នាំទី ៣។ សិស្សអនុវត្តការរៀនសូត្ររបស់ខ្លួនផ្ទាល់ដៃលើកិច្ចការក្នុងជីវភាពពិតប្រាកដ។

**ជំនាញវិជ្ជាជីវៈ និងបំណិនជីវិត**: ដើម្បីជួយសិស្សឱ្យកាន់តែប្រសើរឡើងសម្រាប់ជីវិតប្រកដោយភាពឯករាជ្យ និងជំនាញវិជ្ជាជីវៈ។ សាលាជំនាញសិល្បៈ និងសូនរូប មានគោលបំណងធ្វើឱ្យកម្មវិធីសិក្សាមានលក្ខណៈទូលំទូលាយ តាមរយៈការផ្តល់នូវថ្នាក់រៀនប្រកបដោយជំនាញវិជ្ជាជីវៈ និងបំណិនជីវិត ពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន ទៅជាការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

**កាគាំទ្រការងារ**: បុគ្គលិកពិសេសនៅសាលាជំនាញសិល្បៈសូនរូប ប្រឹងប្រែងជួយគាំទ្រដល់សិស្សក្នុងការស្វែងរកការងារធ្វើ។ អ្នកសម្របសម្រួលការងាររបស់យើងធានាថា សិស្សនឹងត្រៀមខ្លួនជាស្រេចជាមួយនឹងប្រវត្តិរូបសង្ខេបដែលមានជំនាញវិជ្ជាជីវៈ មុខតំណែងសិល្បៈ ជំនាញសំភាសន៍ និងក្រមសីលធម៌ការងារវិជ្ជមាន។

**សកម្មភាពកម្មវិធីសិក្សា**

សិស្សសិក្សាថ្នាក់រៀនត្រៀមរយៈពេល ១ឆ្នាំត្រូវចូលរៀននៅពេលព្រឹក រៀងរាល់ថ្ងៃធ្វើការ (ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ)។ សិស្សសិក្សាកម្មវិធីវិជ្ជាជីវៈសម្រាប់រយៈពេល ៣ឆ្នាំ ត្រូវសិក្សាពេញម៉ោងជារៀងរាល់ថ្ងៃ (ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ) ពីម៉ោង ៨.០០ ព្រឹក ដល់ពេលរសៀល រួមទាំងសិក្ខាសាលាប្រចាំសប្តាហ៍ម្តងម្កាលផងដែរ។

**មុខវិជ្ជាសិក្សា**

សិស្សសិក្សានៅថ្នាក់រៀនត្រៀម ត្រូវសិក្សាមុខវិជ្ជា ដូចជា៖

- ការសំដែងសិល្បៈ
- គំនូរលាបព័ណ៌
- គំនូរ ទស្សនៈ និងម៉ូដ
- គំនូរបែបថ្លុក
- ការរចនា និងកាត់តរូបភាព
- ប្រវត្តិនៃសិល្បៈ

សិស្សសិក្សាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបញ្ចប់ថ្នាក់មូលដ្ឋានឆ្នាំទី ១ រួមមាន៖

- ការសំដែងសិល្បៈ
- គំនូរគ្រោង និងរចនាសម្ព័ន្ធ
- ម៉ូដែល សំឡេង ទស្សនៈ
- ការសរសេរ
- គំនូរជីវចល
- ជំនាញកុំព្យូទ័រ (PS, FL, ID)
- គំនូរ
- រចនាក្រាហ្វិក
- វីដេអូ
- ប្រវត្តិនៃសិល្បៈ និងសិល្បៈខ្មែរ

សិស្សត្រូវជ្រើសរើសមុខវិជ្ជាឯកទេសមួយលើផ្នែក ដូចជា (ការរចនាក្រាហ្វិក គំនូរជីវចល ឬសិល្បៈណាមួយ) បន្ទាប់ពីឆ្នាំទី១។ សិស្សត្រូវសិក្សា និងកំណត់ជំនាញពួកគេជាថ្មីនៅឆ្នាំទី ២ នៅមុនពេលបញ្ចប់កម្មសិក្សា។ នៅឆ្នាំចុងក្រោយនៃការសិក្សា (ឆ្នាំទី ៣) គឺជាឱកាសមួយសម្រាប់សិស្សដើម្បីបង្ហាញពីអ្វីដែលពួកគេបានរៀន និងបង្ហាញពីជំនាញដល់និយោជក *តាមរយៈគម្រោងផ្ទាល់ខ្លួនមួយ*។

**សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីសិក្សារបស់យើង សូមចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំ ឬទាក់ទងបុគ្គលិករបស់សលាជំនាញសិល្បៈសូនរូប។**

ភារងារច្នៃប្រឌិតមានន័យថាត្រូវបង្កើតរឿងថ្មីសម្រាប់មនុស្សជាតិ។
អ្នករៀនអំពីមនុស្ស និងតម្រូវការរបស់មនុស្ស  ហើយចាប់ផ្តើមជំហ៊ានបន្ទាប់បង្កើតអ្វីមួយសម្រាប់មនុស្ស។
យើងលាយបញ្ចូលគ្នានូវប្រពៃណី និងទំនើបកម្មដើម្បីបង្កើតអ្វីមួយថ្មីៗ។
- ប៊ុន សារិន, សិស្សបញ្ចប់ការសិក្សានៅសាលាជំនាញសិល្បៈសូនរូប ដែលបច្ចុប្បន្នជាគ្រូបង្រៀនការរចនាក្រាហ្វិច

**តើអ្នកណាអាចស្នើសុំចូលរៀនបាន?**

**ដើម្បីសិក្សានៅសាលាជំនាញសិល្បៈសូនរូប អ្នកត្រូវតែជាមនុស្ស៖**

•មានគំនិតច្នៃប្រឌិត និងចំណាប់អារម្មណ៍លើសិល្បៈ

•មានអាយុ ១៧ឆ្នាំ ឬលើស

•រស់នៅក្នុងប្រទេសកម្ពុជា។

អ្នកចង់ចូលរៀន ប៉ុន្តែអ្នកគ្មានបទពិសោធន៍ផ្នែកសិល្បៈ ដូចនេះ អ្នកអាចចូលរៀននៅថ្នាក់ត្រៀមរយៈពេល១ឆ្នាំ* **អ្នកត្រូវប្រឡងជាប់ការធ្វើតេស្តចូលរៀន ដើម្បីអាចចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ រយៈពេល ៣ឆ្នាំបាន។**

**ការប្រឡងធ្វើតេស្តចូលរៀន**

ការប្រលងចូលរៀនសម្រាប់កម្មវិធីវិជ្ជាជីវៈ ជាទូទៅមានដូចជា៖

•គូសរូបអំពីម៉ូដែលជីវិត

•ការសំដែងសិល្បៈ

•តេស្តប្រវត្តិសិល្បៈ-អាន សរសេរ សមត្ថភាពនៃការបញ្ចេញមតិ

•ធ្វើតេស្តដោយផ្ទាល់មាត់ជាមួយអ្នកកាត់សេចក្តី -ពន្យល់ពីមូលហេតុដែលអ្នកចង់រៀននៅសាលាជំនាញសិល្បៈសូនរូប និងពិភាក្សាអំពីស្នាដៃសិល្បៈដែលអ្នកបានបង្កើត។ អ្នកមិនចាំបាច់មានបទពិសោធន៍សិល្បៈដើម្បីចូលរួមជាមួយសាលាជំនាញសិល្បៈសូនរូបឡើយ អ្នកគ្រាន់តែមានឆន្ទៈ និងចំណង់ចំណូលចិត្តលើសិល្បៈទៅបានហើយ!

* ក្នុងករណីសាលា មានបេក្ខជនច្រើនចូលរួមវគ្គរៀនត្រៀម សិស្សមកពីគ្រួសារដែលមានចំណូលទាបនឹងទទួលបានអាទិភាពជាង។

**"បន្ទាប់ពីបញ្ចប់ការសិក្សា សិស្សនឹងមានការងារមួយ .......**
**សាលាមិនខ្វល់ថា អ្នកគឺជាអ្នកមាន ឬអ្នកក្រឡើយ។ សាលាជំនាញសិល្បៈ និងសូនរូប នឹងផ្តល់ឲ្យយើងនូវសម្ភារៈសិក្សាដែលយើងត្រូវការសិក្សាជាមួយ៥**

- មីល កុសល សិស្សបញ្ចប់ការសិក្សាពីសាលាជំនាញសិល្បៈសូនរូប អ្នកបង្កើតគំនូរជីវចលស្ទូឌីយូប្រកបដោយភាពច្នៃប្រឌិត



**កម្មវិធី និងថ្លៃសិក្សា** *Photography © Sebastia Galbany*

ឥតគិតថ្លៃសម្រាប់ថ្នាក់រៀនត្រៀមរយៈពេល ១ឆ្នាំ។

សិស្សដែលមិនមានជំនាញក្នុងការគូររូបអាចស្នើសុំចូលរៀននៅថ្នាក់ត្រៀម ហើយក្នុងករណីសាលាទទួលយកឲ្យសិក្សា នោះការសិក្សាមិនតម្រូវឲ្យបង់ថ្លៃនោះទេ។ សាលាចង់ឲ្យសិល្បៈមានគ្រប់ទីកន្លែងចំពោះប្រជាជនកម្ពុជា ហេតុនេះហើយ ទើបសាលាចេញថ្លៃសិក្សាក្នុងឆ្នាំនេះ ដែលនឹងជួយដល់សិស្សនានានៅពេលសិក្សាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។

**តម្លៃ USD ៦០០០** សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរយៈ ៣ឆ្នាំ នៅសាលាជំនាញសិល្បៈសូនរូប។

សិស្សម្នាក់ត្រូវបង់ថ្លៃសិក្សាប្រហែល **USD** ២០០០ ក្នុងមួយឆ្នាំ ឲ្យទៅសាលាដោយផ្ទាល់។ ក្រៅពីគ្រូបង្រៀនដែលមានសមត្ថភាពហើយ សិស្សដែលសិក្សានៅសាលាជំនាញសិល្បៈសូនរូប អាចប្រើប្រាស់នូវគ្រឿងបរិក្ខារដ៏ល្អឥតខ្ចោះរួមមាន: កុំព្យូទ័រជាង៤០គ្រឿង ជាមួយនឹងកម្មវិធីរចនាក្រាហ្វិច និងកម្មវិធីគំនូរជីវចល កាមេរ៉ា និងឧបករណ៍ល្អៗ ស្ទូឌីយោសម្លេង និងស្ទូឌីយោរូបថតត្រូវបានបំពាក់គ្រប់គ្រាន់នៅក្នុងបណ្ណាល័យសិល្បៈ ។

គោលដៅសាលាបើកទូលាយចំពោះសិស្សគ្រប់រូប និងធ្វើសហប្រតិបត្តិការជាសាលាមិនស្វែងរកប្រាក់ចំណេញ។ សាលាទទួលបានជំនួយមួយចំនួន ហើយសាលាក៏បានចូលរួមបង់ប្រាក់ថ្លៃសិក្សាផងដែរ **ហេតុនេះហើយបានជាប្រាក់បង់ថ្លៃសិក្សាប្រចាំឆ្នាំសម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានកាត់បន្ថយទៅដល់ USD ៧២០។**

ខណៈដែលសិស្សរំពឹងការវិនិយោគរបស់ខ្លួនលើការអប់រំ មានជម្រើសជាច្រើនសម្រាប់សិស្សក្នុងការបង់ប្រាក់ក្រោមកម្មវិធីជំនួយហិរញ្ញវត្ថុ។

**គ្រួសារខ្ញុំអាចរ៉ាប់រងលើការចំណាយទាំងស្រុង**

- ដាក់ពាក្យសុំចូលរៀន ហើយជាប់តេស្តចូលរៀន
- ចុះឈ្មោះជា "សិស្សបង់ថ្លៃសិក្សាពេញ"
- បង់ USD ៧២០ ទៅសាលាជំនាញសិល្បៈសូនរូប
- ចាប់ផ្តើមចូលរៀន

**គ្រួសារខ្ញុំមិនអាចរ៉ាប់រងលើការចំណាយពេញលេញបានទេ**

- ដាក់ពាក្យសុំចូលរៀន ហើយជាប់តេស្តចូលរៀន
- បំពេញទម្រង់ **ការវាយតម្លៃអំពីស្ថានភាពគ្រួសារ**
- យល់ព្រមចំពោះកញ្ចប់ជំនួយហិរញ្ញវត្ថុ
- ចាប់ផ្តើមចូលរៀន បង់ប្រាក់មកសាលាវិញ តាមជំរើសជំនួយហិរញ្ញវត្ថុ

*ល័ក្ខខ័ណ្ឌនៃការបង់រំលោះត្រូវបានអនុវត្ត

យើងជឿជាក់ថាការអប់រំគួរតែមានចំពោះអ្នករាល់គ្នា

### ជំនួយហិរញ្ញវត្ថុសម្រាប់សិស្ស

ជំនួយហិរញ្ញវត្ថុគឺជាគំនិតផ្តួចផ្តើមថ្មីមួយដែលធានាថា កម្មវិធីវិជ្ជាជីវៈរបស់សាលាជំនាញសិល្បៈសូនរូប អាចទទួលបានសម្រាប់សិស្សកម្ពុជា ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ច ឬសង្គមរបស់មនុស្សម្នាក់។ ជំនួយហិរញ្ញវត្ថុមានពីរប្រភេទរួមមាន អាហារូបករណ៍ និងជម្រើសបង់ប្រាក់។

### តើអ្នកណាអាចទទួលបានជំនួយហិរញ្ញវត្ថុនេះ?

ដើម្បីមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ សិស្សត្រូវតែជាប្រជាជនកម្ពុជាមកពីគ្រួសារដែលមានចំណូលទាប ហើយបានចុះឈ្មោះសិក្សាក្នុងកម្មវិធីវិជ្ជាជីវៈរយៈពេល ៣ឆ្នាំ។ ក្រុមការងារជួយដល់សង្គមរបស់អង្គការហ្វារពន្លឺសិល្បៈ នឹងវាយតំលៃតម្រូវការគ្រួសារដើម្បីកំណត់ និងកម្រិតពីជំនួយហិរញ្ញវត្ថុ។

**សិស្សដែលចុះឈ្មោះចូលរៀនក្នុងវគ្គត្រៀម មិនចាំបាច់បង់ថ្លៃសិក្សា ហើយមិនមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុឡើយ។ កញ្ចប់ជំនួយហិរញ្ញវត្ថុ និងអាហារូបករណ៍ អាចមាននៅពេលសិស្សចូលរៀនក្នុងកម្មវិធីវិជ្ជាជីវៈ ហើយត្រូវបង់ថ្លៃសិក្សាប្រចាំឆ្នាំ។**

### អាហារូបករណ៍

សិស្សមកពីគ្រួសារដែលមានប្រាក់ចំណូលទាប អាចទទួលបានការឧបត្ថម្ភមួយផ្នែក ឬទាំងស្រុងដែលនឹងកាត់បន្ថយថ្លៃសិក្សាប្រចាំឆ្នាំរបស់ពួកគេ។ ការវាយតម្លៃស្ថានភាពគ្រួសារដែលធ្វើឡើងដោយក្រុមការងារជួយដល់សង្គមរបស់យើង នឹងកំណត់ពីចំនួនទឹកប្រាក់អាហារូបករណ៍ឲ្យត្រូវផ្តល់ជូន។

សិស្សក៏អាចស្វែងរកអាហារូបករណ៍ពីអង្គការក្រៅរដ្ឋាភិបាល ឬប្រភពដទៃទៀតផងដែរ។ នៅពេលចំនួនទឹកប្រាក់ USD ៧២០ នៃអាហារូបករណ៍ត្រូវបានដកចេញនោះ សិស្ស ព្រមទាំងឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេអាចប្រើប្រើប្រាស់នូវ "ជម្រើសសងប្រាក់វិញ" ដើម្បីសងប្រាក់ដែលនៅសល់ ។ ប្រសិនបើសិស្សមិនបំពេញបានតាមលក្ខខណ្ឌដើម្បីទទួលបានអាហារូបករណ៍នោះទេ ពួកគេនៅតែអាចមានសិទ្ធិក្នុងការស្នើសុំកញ្ចប់ជំនួយផ្នែកហិរញ្ញវត្ថុ។

### កញ្ចប់ជំនួយហិរញ្ញវត្ថុ

- **វិភាគទានប្រចាំខែ**: គ្រួសារ ឬអាណាព្យាបាលរបស់សិស្ស អាចបង់ប្រាក់ដែលពួកគេអាចមាន ជារៀងរាល់ខែដូចជា ១០ ដុល្លារ ក្នុងមួយខែ។
- **ធ្វើការងារនៅសាលា**: មានឱកាសការងារច្រើននៅសាលារៀន ដែលអាចឲ្យសិស្សសងប្រាក់វិញតាមរយៈការធ្វើការងារតាមម៉ោងដែលបានកំណត់។
- **ប្រាក់កម្ចី**: សិស្សអាចសងប្រាក់ត្រឡប់មកវិញតាមកម្ចីដែលមិនមានការប្រាក់ នៅពេលពួកគេបញ្ចប់ការសិក្សា ហើយចាប់ផ្តើមរកប្រាក់ចំណូល។ បទបញ្ញត្តិ និងល័ក្ខខ័ណ្ឌផ្សេងៗត្រូវបានអនុវត្ត។

**ឧទាហរណ៍នានានៃជំនួយហិរញ្ញវត្ថុ**

| | អាហារូបករណ៍ | កញ្ចប់ជំនួយហិរញ្ញវត្ថុ | | | សរុប |
|---|---|---|---|---|---|
| | | កម្ចីសម្រាប់សិស្ស | ការងារនៅសាលា | បង់ប្រាក់ជាជំហាន | |
| សិស្ស 1 | $200 | $300 | $220 / ម៉ោង | គ្មាន | |
| សិស្ស 2 | $100 | $340 | $100 / ម៉ោង | $180 *($15 x 12)* | |
| សិស្ស 3 | គ្មាន | $140 | $200 / ម៉ោង | $360 *($30 x 12)* | $720.00 |
| សិស្ស 4 | គ្មាន | គ្មាន | $220 / ម៉ោង | $500 *($250 x 2 )* | |
| សិស្ស 5 | គ្មាន | គ្មាន | គ្មាន | $720 *($180 x 4)* | |

ស្ថានភាពគ្រួសារនីមួយៗមានភាពខុសគ្នាពីមួយទៅមួយ។ សម្រាប់គ្រួសារដែលអាចបង់ "ចំណែកប្រចាំខែ" បានច្រើនជាង សិស្សនោះនឹងត្រូវធ្វើការងារតិចជាង និងគ្មានប្រាក់កម្ចី។ ដើម្បីស្របតាមស្ថានភាពអ្នករាល់គ្នា ក្រុមការងារជួយដល់សង្គមរបស់អង្គការហ្វារពន្លឺសិល្បៈនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រួសារនីមួយៗ ដើម្បីបង្កើតកញ្ចប់ជំនួយហិរញ្ញវត្ថុ។

**នាពេលបច្ចុប្បន្ន សិស្សដែលកំពុងរស់នៅក្រៅខេត្តបាត់ដំបងត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យចូលរៀននៅសាលាជំនាញសិល្បៈសូនរូប។**

ប្រសិនបើត្រូវបានទទួលយកឲ្យចូលរៀន សាលានឹងជួយស្វែងរកកន្លែងស្នាក់នៅក្នុងខេត្តបាត់ដំបង។ សិស្សដែលមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុក៏អាចទទួលបានការឧបត្ថម្ភថវិកាផងដែរដើម្បីបង់ថ្លៃស្នាក់នៅ និងការរស់នៅ។

**ការឧបត្ថម្ភសម្រាប់សិស្សដែលបានចុះឈ្មោះនៅថ្នាក់រៀនត្រៀម**

សិស្សមួយចំនួនក្នុងថ្នាក់រៀនត្រៀមអាចមានសិទ្ធិទទួលបានការជួយឧបតម្ភផ្នែកសង្គម (ឧទាហរណ៍ការហូបអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃ និងសម្ភារៈប្រើប្រាស់ជាដើម)។ ការវាយតម្លៃស្ថានភាពគ្រួសារនឹងកំណត់ពីកម្រិតនៃការឧបត្ថម្ភ។

**តើខ្ញុំត្រូវស្នើសុំជំនួយហិរញ្ញវត្ថុដោយរបៀបណា ?**

ដាក់ពាក្យ
- **កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ** ជ្រើសរើស "ជំនួយហិរញ្ញវត្ថុ" ក្នុងពាក្យសុំ និងផ្តល់ព័ត៌មានលម្អិតពីស្ថានភាពអ្នក

ដំណើរការពាក្យសុំ
- **វាយតម្លៃតម្រូវការគ្រួសារ:** បុគ្គលិកផ្នែកសង្គមនឹងទៅដល់ផ្ទះរបស់អ្នកដើម្បីប្រមូលព័ត៌មានសង្គម និងសេដ្ឋកិច្ច

ទទួលយកចូលរៀន
- **ផ្តល់ជំនួយហិរញ្ញវត្ថុ:** សិស្ស គ្រួសារ ឬអាណាព្យាបាលរបស់ពួកគេនឹងពិនិត្យនូវជម្រើស(ខាងលើ) ដើម្បីបង់ថ្លៃសាលា
- **កិច្ចព្រមព្រៀង និងលិខិតប្តេជ្ញានៃជំនួយហិរញ្ញវត្ថុ**

## របៀបស្នើសុំចូលរៀន

### ១. ដាក់ពាក្យសុំចូលរៀនតាមអនឡាញ ឬជាទម្រង់លិខិត

ទម្រង់ពាក្យសុំចូលរៀនជាលិខិត ត្រូវដាក់ដោយផ្ទាល់ទៅបុគ្គលិកបម្រើការនៅសាលាជំនាញសិល្បៈសូនរូប ឬនៅអង្គការហ្វារពន្លឺសិល្បៈក្នុងខេត្តបាត់ដំបង។ ទម្រង់ពាក្យសុំចូលរៀនតាមប្រព័ន្ធអនឡាញអាចដាក់បានពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។ នៅពេលអ្នកដាក់ពាក្យសុំចូលរៀន អ្នកអាចស្នើសុំ**ជំនួយហិរញ្ញវត្ថុ** (សូមមើលទំព័រទី ៧ សម្រាប់ព័ត៌មានលំអិត)។ អ្នកត្រូវភ្ជាប់មកជាមួយឯកសារថតចម្លង (ជាទម្រង់លិខិត ឬជាទម្រង់អេឡិចត្រូនិក)៖ សៀវភៅគ្រួសារ (ព័ត៌មានអំពីឪពុកម្តាយ)។ សំបុត្រកំណើតរបស់សិស្ស រូបថត២សន្លឹកប៉ុនទំហំដែលបិទលើលិខិតឆ្លងដែន សូមចូលទៅកាន់គេហទំព័ររបស់អង្គការហ្វារពន្លឺសិល្បៈ ឬទំព័រហ្វេសប៊ុកសម្រាប់កាលបរិច្ឆេទដាក់ពាក្យសុំចូលរៀន។

### ២. ចូលរួមធ្វើតេស្តប្រឡងចូលរៀននៅអង្គការហ្វារពន្លឺសិល្បៈ

**ថ្នាក់រៀនត្រៀម**៖ មិនតម្រូវឱ្យមានការធ្វើតេស្តឡើយ។

**កម្មវិធីវិជ្ជាជីវៈ** រាល់អ្នកដាក់ពាក្យស្នើសុំចូលរៀនសម្រាប់វគ្គសិក្សារយៈពេល ១ឆ្នាំ ត្រូវធ្វើតេស្តសាកល្បង បន្ទាប់ពីបានដាក់ពាក្យស្នើសុំចូលរៀនរួច។ ការធ្វើតេស្តនេះត្រូវចំណាយពេល ២ ថ្ងៃ៖ ថ្ងៃទី១ ប្រឡងតេស្តសរសេរ និងថ្ងៃទី ២ គឺតេស្តផ្ទាល់មាត់រយៈពេល ១៥នាទី។ សូមយកឧទាហរណ៍ណាមួយនៃស្នាដៃសិល្បៈរបស់អ្នក (គំនូរ ការគូររូប វីដេអូ) ទៅកាន់កន្លែងធ្វើតេស្តផ្ទាល់មាត់។ ប្រសិនបើអ្នកជាសិស្សក្នុងប្រទេសកម្ពុជា អ្នកត្រូវតែមកដល់ខេត្តបាត់ដំបងយ៉ាងហោចណាស់មួយយប់មុនថ្ងៃធ្វើតេស្តដំបូង។ កាលបរិច្ឆេទធ្វើតេស្ត នឹងត្រូវបានជូនដំណឹងនៅលើគេហទំព័រ និងទំព័រហ្វេសប៊ុករបស់សាលា។

### ៣. ជួបជាមួយក្រុមការងារជួយដល់សង្គម *

**ក្នុងករណីអ្នកបានស្នើសុំជំនួយហិរញ្ញវត្ថុ**៖ ក្រុមការងារជួយដល់សង្គមរបស់យើងនឹងទៅជួបអ្នកគ្រួសារ ឬអាណាព្យាបាល ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពគ្រួសារ។ ការវាយតម្លៃនេះនឹងស្ទាបស្ទង់អំពីប្រាក់ចំណូលរបស់អ្នក និងកំណត់ថាតើ អ្នកនឹងទទួលបានការឧបត្ថម្ភប៉ុន្មាន។ ការវាយតម្លៃស្ថានភាពគ្រួសារនឹងត្រូវបានបញ្ចប់នៅក្នុងខែសីហា។ រាល់ការវាយតម្លៃនីមួយៗត្រូវចំណាយពេល ២-៣ ម៉ោង។

**ប្រសិនបើអ្នក<u>មិន</u>បានស្នើសុំជំនួយហិរញ្ញវត្ថុ**៖ អ្នកអាចបន្តទៅកាន់ជំហានទី៤។

### ៤. យល់ព្រមនឹងពាក្យស្នើសុំរបស់អ្នក

អ្នកអាចមានជម្រើសផ្ទាល់ខ្លួនមួយដើម្បីជ្រើសរើសការសិក្សាក្នុងថ្នាក់រៀនត្រៀម ឬនៅឆ្នាំទី១នៃវគ្គ បណ្តុះបណ្តាលវិជ្ជាជីវៈ។ សំណើរបស់អ្នកត្រូវបញ្ចូលនូវព័ត៌មានលម្អិតនៃផែនការជំនួយហិរញ្ញវត្ថុដែលអ្នកត្រូវយល់ព្រមចុះឈ្មោះចូលរៀន។

## ៥. ត្រៀមរៀបចំការសិក្សារបស់អ្នក!

សាលានឹងផ្តល់ជូនការតម្រង់ទិសក្នុងរយៈពេលពីរបីថ្ងៃដំបូង។ សិស្សដែលរស់នៅតាមបណ្តាខេត្តផ្សេងៗទៀតនៃប្រទេសកម្ពុជា នឹងទទួលបានការផ្តល់យោបល់ពីការផ្លាស់ទីលំនៅមកកាន់ខេត្តបាត់ដំបង។ ឆ្នាំសិក្សាថ្មីចាប់ផ្តើមជាធម្មតានៅសប្តាហ៍ទី២ ក្នុងខែកញ្ញា។ កាលបរិច្ឆេទចាប់ផ្តើមចូលរៀនអាចរកឃើញនៅលើគេហទំព័រ និងហ្វេសប៊ុករបស់យើងខ្ញុំ។

**សំណួរដែលត្រូវបានសួរភាគច្រើន**

**តើខ្ញុំអាចរំលងថ្នាក់ត្រៀម ហើយចូលរៀនឆ្នាំទី ១ បានដែរឬទេ?**

ប្រាកដជាបាន ប្រសិនបើអ្នកទទួលបានពិន្ទុខ្ពស់ពីការធ្វើតេស្តចូលរៀននោះ គឺអ្នកអាចរំលងវគ្គរៀនត្រៀម ហើយចូលរៀននៅឆ្នាំទី ១ នៃកម្មវិធីបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈបាន។ ប្រសិនបើអ្នកចង់ចូលរៀន ឆ្នាំទី ១ អ្នកត្រូវបង្ហាញឧទាហរណ៍នៃស្នាដៃសិល្បៈរបស់អ្នកក្នុងកំឡុងពេលធ្វើតេស្តផ្ទាល់មាត់ (ដូចជាគំនូរ ការគូររូបព្រាង រូបចម្លាក់ ឬរូបថតរូបជាដើម)។ នៅក្នុងការប្រឡងផ្ទាល់មាត់ អ្នកត្រូវការនិយាយអំពីសិល្បៈរបស់អ្នកនិងហេតុផលដែលអ្នកចង់សិក្សានៅសាលាជំនាញសិល្បៈសូនរូប។

**តើខ្ញុំចាំបាច់ត្រូវមានបទពិសោធន៍ផ្នែកសិល្បៈដើម្បីសុំចូលរៀននៅសាលាជំនាញសិល្បៈសូនរូបដែរឬទេ?**

មិនចាំចាច់នោះទេ អ្នកគ្រាន់តែមានចំណាប់អារម្មណ៍ ហើយចង់ស្នើសុំចូលរៀនទៅបានហើយ! ប្រសិនបើអ្នកមិនមានបទពិសោធន៍នោះទេ អ្នកអាចចូលរួមក្នុងថ្នាក់រៀនត្រៀមរយៈពេល ១ឆ្នាំ ហើយក្រោយមកអ្នកអាចសុំចូលរៀនកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈបានហើយ។

**តើការបណ្តុះបណ្តាលវិជ្ជាជីវៈនេះត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំកម្ពុជា ដែរឬទេ?**

សាលាជំនាញសិល្បៈសូនរូបនៃអង្គការហ្វារពន្លឺសិល្បៈ ជ្រើសរើសអនុវត្តកម្មវិធីសិក្សាឯកទេសដែលនឹងជួយឲ្យសិស្សមានជំនាញ និងសមត្ថភាពឲ្យទាន់នឹងសម័យកាលចុងក្រោយ។ ប្រសិនបើយើងមិនអនុវត្តតាមកម្មវិធីសិក្សាក្រសួងអប់រំទេ នោះក្រសួងមិនទទួលស្គាល់ជាផ្លូវការនូវវិញ្ញាបនបត្ររបស់យើងឡើយ។ ទោះជាយ៉ាងណា អង្គការហ្វារពន្លឺសិល្បៈធ្វើសហប្រតិបត្តិការក្រោមការណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈព្រមទាំងមានការចុះអនុស្សរណៈយោគយល់ជាមួយគ្នាផងដែរ។ លើសពីនេះទៀត ការសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ និងអាជ្ញាធរខេត្តក៏ត្រូវបានសហការគ្នាយ៉ាងជិតស្និទ្ធផងដែរ។ អភិបាលខេត្តតែងតែចូលរួមក្នុងពិធីបញ្ចប់ការសិក្សារបស់យើង ហើយសរសើរសិស្សរបស់យើងចំពោះសមិទ្ធផលរបស់ពួកគេ។ អ្នកអាចជឿជាក់ថាវិញ្ញាបនប័ត្រពីសាលាជំនាញសិល្បៈសូនរូប នឹងមានភាពគ្រប់គ្រាន់សម្រាប់ចាប់ផ្តើមអាជីពរបស់អ្នកនៅក្នុង វិស័យសិល្បៈ ការរចនាក្រាហ្វិក និងឧស្សាហកម្មគំនូរជីវចល។

**បច្ចុប្បន្ន ខ្ញុំមិនបានរស់នៅក្នុងខេត្តបាត់ដំបងទេ ប៉ុន្តែខ្ញុំក៏ចង់ទៅរៀននៅសាលាជំនាញសិល្បៈសូនរូបដែរ។ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច?**

អ្នកត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យសុំចូលរៀននៅ និងចូលរួមការធ្វើតេស្តចូលរៀននៅសាលាជំនាញសិល្បៈសូនរូប។ អ្នកអាចមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុទាំងថ្លៃសិក្សា និងការរស់នៅដែលនឹងអនុញ្ញាតឱ្យអ្នកទទួលបានការឧបត្ថម្ភដើម្បីរស់នៅក្នុងខេត្តបាត់ដំបងក្នុងរយៈពេលនៃកម្មវិធីសិក្សារៀនសូត្រ។ សូមទាក់ទងមកយើងខ្ញុំ យើងអាចផ្តល់ដំបូន្មានបន្ថែមដោយផ្ទាល់។

**តើខ្ញុំអាចរកចំណូលបានដែរឬទេ ក្នុងអំឡុងពេលសិក្សា?**

ប្រាកដជាបាន សិស្សអាចធ្វើការងារ ប្រសិនបើពួកគេប្រឡងជាប់ការធ្វើតេស្តទាំងអស់របស់ខ្លួន និងបញ្ចប់វគ្គសិក្សាទៅតាមស្តង់ដារដែលតម្រូវ។ ជាទូទៅ សាលារៀនបើកពីម៉ោង ៨ ព្រឹក ដល់ម៉ោង ៥ល្ងាច ដូចនេះ សិស្សមានពេលវេលាពេលល្ងាច និងពេលចុងសប្តាហ៍ដើម្បីធ្វើការងាររបស់ខ្លួនបាន។ លើសពីនេះទៀត ឱកាសការងារផ្សេងៗអាចរកបាននៅតាមបរិវេណសាលា និងតាមរយៈសហគ្រាសសង្គមរបស់សាលារៀន-ដែលមានឈ្មោះថា សូឌីយូច្នៃប្រឌិតអង្គការហ្វារ។ សិស្សសាលាជំនាញសិល្បៈសូនរូបជាច្រើនរូប ចាប់ផ្តើមរកបានប្រាក់ចំណូលពីជំនាញច្នៃប្រឌិតរបស់ខ្លួន (ឧទាហរណ៍ ការរចនាក្រាហ្វិក ការគូសគំនូរតាមសណ្ឋាគារ និងផ្ទះសំណាក់ និងគំនូរនៅជញ្ជាំងជាដើម)។

**តើក្រុមគ្រួសារចូលរួមក្នុងការសិក្សានេះឬទេ?**

សៀវភៅទំនាក់ទំនងមួយក្បាលត្រូវបានបង្កើតឡើងដើម្បីភ្ជាប់ទំនាក់ទំនងសាលាទៅនឹងក្រុមគ្រួសារ និងគ្រូបង្រៀន។ អវត្តមាន សមិទ្ធផល និងព្រឹត្តិការណ៍នានាត្រូវបានតាមដាននៅក្នុងសៀវភៅនេះ។ ក្រុមគ្រួសារ ឬគ្រូបង្រៀនត្រូវបានតម្រូវឲ្យចុះហត្ថលេខាជាទៀងទាត់ដើម្បីធានាថា សិស្សទទួលបានការឧបត្ថម្ភគ្រប់គ្រាន់ក្នុងការសិក្សារបស់ពួកគេ។ នៅដើម និងចុងបញ្ចប់នៃឆ្នាំសិក្សា សាលាមានរៀបចំកិច្ចប្រជុំជាមួយមាតាបិតាដើម្បីចែករំលែកព័ត៌មានរវាងសាលារៀន សិស្ស និងឪពុកម្តាយ។ ក្នុងអំឡុងពេលប្រជុំទាំងនេះ ក្រុមគ្រួសាររបស់ពួកគេអាចលើកឡើងនូវកង្វល់ណាមួយដែលមាន។

**តើសិស្សពិការភាពអាចសិក្សានៅសាលាជំនាញសិល្បៈសូនរូប បានដែរឬទេ?**

សាលាជឿជាក់ថា សិស្សពិការភាពមានសិទ្ធិសិក្សាជាមួយអ្នកដែលមិនពិការភាព តាមដែលអាចធ្វើទៅបាន។ សាលាខិតខំដើម្បីបំពេញតាមតម្រូវការរបស់អ្នកសិក្សាទាំងអស់តាមករណីមួយៗ។ សូមសាកសួរមកកាន់ផ្នែកជួយដល់សង្គមរបស់យើងខ្ញុំ សម្រាប់ព័ត៌មានបន្ថែម។

**សិស្សបច្ចុប្បន្នដែលកំពុងរស់នៅក្រៅខេត្តបាត់ដំបង**

បច្ចុប្បន្ន សិស្សដែលកំពុងរស់នៅក្រៅខេត្តបាត់ដំបង ត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យចូលរៀននៅសាលាជំនាញសិល្បៈសូនរូប។ ប្រសិនបើត្រូវបានអនុញ្ញាតឲ្យចូលរៀន សាលានឹងឧបត្ថម្ភអ្នក ស្វែងរកកន្លែងស្នាក់នៅក្នុងខេត្តបាត់ដំបង។ សិស្សដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុក៏អាចទទួលបានការឧបត្ថម្ភថវិកាផងដែរដើម្បីបង់ថ្លៃស្នាក់ នៅនិងការរស់នៅរបស់ពួកគេ។

**ហេតុអ្វីបានជាខ្ញុំគួរតែផ្លាស់មកកាន់ខេត្តបាត់ដំបង ដើម្បីសិក្សា?**

- **ខេត្តដែលប្រកបដោយភាពច្នៃប្រឌិតរបស់ប្រទេសកម្ពុជា**: បាត់ដំបងជាកន្លែងបណ្តុំសិល្បៈ ហាងលក់ទំនិញ និងអ្នកជំនាញខាងច្នៃប្រឌិត។ ស្ថាបត្យកម្មនៅខេត្តបាត់ដំបងទទួលឥទ្ធិពលពីប្រទេសបារាំង ដូច្នេះអ្នកនឹងរីករាយដើរជុំវិញទីក្រុងដ៏ស្រស់ស្អាតរបស់យើង។

- **លំហែកាយ និងស្ងប់ស្ងាត់**: បាត់ដំបងមានកន្លែងល្អជាច្រើន ភោជនីយដ្ឋាន និងកន្លែងទាក់ទាញ គ្មានចរាចរមមាញឹក និងសម្លេងរំខានឡើយ។
- **សុវត្ថិភាព**: ខេត្តបាត់ដំបងមានអត្រាបទល្មើសទាបដែលធ្វើឱ្យខេត្តនេះក្លាយជាទីខេត្តដ៏អស្ចារ្យមួយសម្រាប់សិស្សរស់នៅ។
- **សាលារៀនទទួលស្វាគមន៍**: នៅពេលអ្នកចូលរួមជាមួយសាលាជំនាញសិល្បៈសូនរូប អ្នកបានក្លាយជាផ្នែកមួយនៃគ្រួសារច្នៃប្រឌិតរបស់អង្គការហ្វារពន្លឺសិល្បៈ។ នៅអង្គការហ្វារពន្លឺសិល្បៈ អ្នកអាចបង្កើតមិត្តភក្តិជាមួយមនុស្សដែលមានគំនិតច្នៃប្រឌិត និងបុគ្គលិកផ្នែកផ្សេងៗទៀត (ដូចជា សិល្បៈសំដែង តន្ត្រី ល្ខោន ជាដើម)។
- **ការអប់រំតែមួយគត់**: សលាជំនាញសិល្បៈសូនរូបជាសាលាឈានមុខគេមួយ ផ្នែកផលិតគំនូរជីវចលការរចនាក្រាហ្វិក និងគំនូរជីវចល។ សិស្សដែលបញ្ចប់ការសិក្សា ត្រូវបានទទួលយកឲ្យធ្វើជាបុគ្គលិកនៅទូទាំងប្រទេសកម្ពុជា និងអន្តរជាតិ។ ប្រសិនបើអ្នកចង់បម្រើការងារនៅក្នុងឧស្សាហកម្មច្នៃប្រឌិតសាលាជំនាញសិល្បៈសូនរូបនឹងផ្តល់ជូននូវវគ្គបណ្តុះបណ្តាលទាន់សម័យបំផុត។

## ទស្សនៈទានរបស់សិស្ស

## ខាន់ ចាន់ថន សិស្សសិក្សាផ្នែកគំនូរជីវចល



ខ្ញុំគឺជាសិស្សសិក្សាថ្នាក់គំនូរជីវចល ហើយខ្ញុំជឿជាក់លើសមត្ថភាពរបស់ខ្ញុំក្នុងការធ្វើការនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំមានឱកាសដែលជាមុខរបរមួយផ្នែកសិល្បៈ និងសមត្ថភាពធ្វើការងារឈរលើម្ចាស់ការខ្លួនឯង ក្នុងការជ្រើសរើស និងផ្តល់អាទិភាពដល់ការងារដោយផ្អែកលើចំណាប់អារម្មណ៍របស់ខ្ញុំ។ យុវជនពេញវ័យគួរតែសិក្សានៅអង្គការហ្វារពន្លឺសិល្បៈ ព្រោះថាសិស្សនឹងក្លាយទៅជាសិល្បករជំនាញផ្អែកលើជំនាញដែលពួកគេបានជ្រើសរើស។ ខ្ញុំជឿជាក់ថា ខ្ញុំអាចទទួលបានការងារល្អបន្ទាប់ពីបញ្ចប់ការសិក្សា។

## សន ស្រីនាង សិស្សបញ្ចប់ការសិក្សាផ្នែកគំនូរជីវចល



ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលបានសិក្សានៅសាលាជំនាញសិល្បៈសូនរូប ព្រោះមានអារម្មណ៍ថាដូចជាផ្ទះរបស់ខ្ញុំ ហើយខ្ញុំទទួលបានការស្វាគមន៍យ៉ាងខ្លាំង។ គ្រូបង្រៀនមានគុណភាពល្អ ហើយខ្ញុំអាចជ្រើសរើសជំនាញដែលមានច្រើនប្រភេទ។ ការងារច្នៃប្រឌិតផ្នែកគំនូរជីវ ចលគឺជាជំនាញដ៏កម្រមួយនៅក្នុងប្រទេសកម្ពុជា មានន័យថា នៅពេលដែលអ្នកចេះជំនាញនេះអ្នកនឹងមានអាទិភាពនៅក្នុងទីផ្សារការងារ។ វាក៏ជាការងារដែលខ្ញុំស្រលាញ់ ហើយខ្ញុំមិនដែលធុញទ្រាន់ឡើយ។ ខ្ញុំចង់ អោយសិស្សកាន់តែច្រើនចូលរួមកម្មវិធីនេះ ព្រោះវាជារឿងល្អសម្រាប់សិស្សជំនាន់ក្រោយក្លាយជាសិល្បៈករ។

## លីម ស្រីលាង សិស្សបញ្ចប់ការសិក្សា និងជាឌីហ្សាញ



ខ្ញុំចាប់ផ្តើមអាជីពរបស់ខ្ញុំជាឌីហ្សាញ ស្របពេលខ្ញុំរៀននៅសាលាគណនេយ្យផងដែរ។ នៅពេលដែលខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅសកលវិទ្យាល័យ ខ្ញុំបានមកសិក្សាថ្នាក់ពេញម៉ោងនៅសាលាជំនាញសិល្បៈសូនរូប។

នៅពេលខ្ញុំមកទីនេះជាលើកដំបូង ខ្ញុំបានរកឃើញនូវគ្រួសារមួយដែលមិនគ្រាន់តែជាមិត្តភក្តិប៉ុណ្ណោះទេ។ យើងសិក្សាជាមួយគ្នា យើងធ្វើអ្វីៗទាំងអស់រួមគ្នា។

នៅពេលដែលយើងមានបញ្ហាយើងតែងតែដោះស្រាយវា។ វាមិនមែនជាជំនាញដែលអ្នកគ្រាន់តែសិក្សា ហើយស្វែងរកការងារធ្វើនោះទេ។ នេះជាការងារមួយប្រកបដោយទេពកោសល្យ។ នៅពេលដែលអ្នកមានសេរីភាពចេញទៅពិភពខាងក្រៅនោះ អ្នកនឹងអាចបង្កើតអ្វីថ្មីៗបាន។

**ឱកាសការងារ**

នៅពេលសិស្សបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួននៅសាលាជំនាញសិល្បៈសូនរូបហើយ ពួកគេនឹងត្រូវបានជ្រើសរើសធ្វើការងារជាអ្នកជាម្ចាស់ការលើខ្លួនឯង ក្នុងការប្រកបការអាជីវកម្មផ្ទាល់ខ្លួន ឬបម្រើការងារក្រុមហ៊ុន ឬអង្គការនានា។ នេះគឺជាវិថីនៃមុខរបរមួយចំនួន ដែលសិស្សបញ្ចប់ការសិក្សាអាចជ្រើសរើសដើម្បីធើបាន៖

**អ្នកបង្កើតគំនូរជីវចល** ផលិតរឿង និងក្រាហ្វិក ដោយប្រើ ២D ឬ ៣D ដែលត្រូវបានប្រើនៅក្នុងពិធីបុណ្យ ការផ្សាយពាណិជ្ជកម្ម និងការអប់រំ។ អ្នកបង្កើតគំនូរប្រើបច្ចេកវិទ្យា និងជំនាញគូរគំនូរ ព្រមទាំងធ្វើការទទួលប្រាក់ពីអតិថិជន។ ឧស្សាហកម្មគំនូរជីវចលកំពុងតែរីកចម្រើននៅក្នុងប្រទេសកម្ពុជា។ សាលាជំនាញសិល្បៈសូនរូប កំពុងបង្រៀនសិស្សដើម្បីស្វែងរកអាជីពជាអ្នកបង្កើតគំនូរជីវចលដ៏ ជំនាញ។

**អ្នករចនាក្រាហ្វិក** បង្កើតនូវសម្ភារៈសូនរូបសំរាប់ផលិតផល និងសកម្មភាពនានា ដូចជាស្លាកសញ្ញា គេហទំព័រ ការផ្សាយពាណិជ្ជកម្ម សៀវភៅ ទស្សនាវដ្ដី ផ្ទាំងរូបភាព ហ្គេមកុំព្យូទ័រ ការវេចខ្ចប់ ផលិតផល ការតាំងពិពណ៌ និងការតាំងបង្ហាញផ្សេងៗ។ អ្នករចនាក្រាហ្វិកបង្កើតគំនិត និងការច្នៃប្រឌិតថ្មីសម្រាប់អតិថិជនផ្សេងៗគ្នា។ ដាក់ពាក្យចូលរៀននៅសលាជំនាញសិល្បៈសូនរូប ដើម្បីចាប់ផ្តើមការធ្វើដំណើររបស់អ្នកនៅក្នុងឧស្សាហកម្មដែលរីកលូតលាស់នៅក្នុងប្រទេសកម្ពុជា។

**វិចិត្រករសូនរូប** បង្កើតសិល្បៈមិនចម្លងពីគេ ដូចជាគំនូរ ចម្លាក់ និងវីដេអូដែលត្រូវបានដាក់បង្ហាញនៅក្នុងវិចិត្រសាល សារមន្ទីរ ឬនៅទីសាធារណៈ។ ការងារសិល្បៈរបស់ពួកគេអាចត្រូវបានលក់ទៅឱ្យអ្នកឯកជន សណ្ឋាគារ ភោជនីយដ្ឋាន ឬអង្គការ។ វិចិត្រករពីអង្គការហ្សារពន្លឺសិល្បៈបានដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាល និងបានធ្វើដំណើរទៅក្រៅប្រទេស។ វិចិត្រសិល្បៈកម្មាក់ក៏អាចចែករំលែកគំនិតច្នៃប្រឌិតរបស់ខ្លួនដើម្បីធ្វើការជាមួយសាលារៀន ទេសចរណ៍សិល្បៈ និងអង្គការសហគមន៍។

**អ្នកជំនាញការទំនាក់ទំនង** ទទួលខុសត្រូវចំពោះទំនាក់ទំនងរបស់ក្រុមហ៊ុនជាមួយភ្ញៀវជាគោលដៅផ្សេងៗគ្នា។ អ្នកជំនាញការទំនាក់ទំនងប្រើជំនាញសរសេរ មើល និងពាក្យសំដីដើម្បីបង្កើតសម្ភារៈទាក់ទង ដូចជាផ្ទាំងរូបភាព និងបទបង្ហាញជាដើម។ ពួកគេក៏អាចគ្រប់គ្រងបណ្តាញសង្គម និងសា អេឡិចត្រូនិកជាមួយអតិថិជនផ្សេងៗគ្នាបានផងដែរ។

**គំនូរបែបបច្ឆុក** ប្រើប្រាស់ជំនាញច្នៃប្រឌិតរបស់ខ្លួនផ្នែកសិល្បៈ និងការរចនាដើម្បីបង្កើតរឿងរ៉ាវ សារឬគំនិត។ អ្នកគំនូរថ្លុក អាចធ្វើការជាមួយអ្នកនិពន្ធដើម្បីផលិតសៀវភៅកំសាន្ត ឬសៀវភៅអប់រំ រឿងកំប្លែង ឬសម្ភារៈផ្សេងទៀត។

**អ្នកបង្កើតគេហទំព័រ** មានគម្រោង បង្កើត និងសរសេរកូដគេហទំព័រដើម្បីឱ្យសមស្របទៅនឹងតម្រូវការអតិថិជន។ ពួកគេប្រើប្រាស់ទិដ្ឋភាពបច្ចេកទេស និងក្រាហ្វិកនៃគេហទំព័រ។ អ្នកបង្កើតគេហទំព័រអាចបង្កើតគេហទំព័រថ្មី ឬរក្សាគេហទំព័រដែលមានស្រាប់ទាំងផ្នែកពាណិជ្ជកម្ម អប់រំ និងស្ថាប័នរដ្ឋាភិបាល។

**ដាក់ពាក្យចូលរៀននៅសាលាជំនាញសិល្បៈសូនរូបដើម្បីចាប់ផ្តើមអាជីពច្នៃប្រឌិតរបស់អ្នក។**

ចំនួននៃអ្នកបញ្ចប់ការសិក្សានៅមានកម្រិត

ស្របពេលដែលតម្រូវការប្រកបដោយវិជ្ជាជីវៈផ្នែកវប្បធម៌មានការកើនឡើង